# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបើកឆ្នាំសិក្សាសាលាអប់រំជំនឿសន្តយ៉ូស្វីនជំនាន់ទី៤
# ភ្នំពេញថ្មី ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩
# គ្រីស្តបរិស័ទត្រូវធ្វើជាទូតនៃសេចក្តីសុខសាន្ត

**អត្ថបទទី១៖ យ៉ូអែល ៤,១២-២១**

ពេលនោះអ្នករាល់គ្នា នឹងទទួលស្គាល់ថា យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា យើងស្ថិតនៅលើភ្នំស៊ីយ៉ូន ជាភ្នំដ៏វិសុទ្ធរបស់យើង ក្រុងយេរូសាឡឹមនឹងបានវិសុទ្ធ ហើយជាតិសាសន៍ដទៃលែងមកឈ្លានពានក្រុងនេះទៀត។ យអ ៤,១៧

**ដំណឹងល្អ៖ លូកា ១១,២៧-២៨**

ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «អ្នកណាស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអនុវត្តតាម គឺអ្នកនោះហើយដែលមានសុភមង្គលពិតមែន»។ លក ១១,២៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះដែលយើងនឹករឭកដល់សម្តេចប៉ាប យ៉ូហានទី២៣ ជាឱកាសមួយដើម្បីនឹកឃើញដល់ទស្សនៈរបស់សម្តេចប៉ាប។ សម្តេចប៉ាប មានទស្សនៈច្រើនណាស់ខ្ញុំសូមលើកយកបីចំណុចដើម្បីជាកម្លាំងសម្រាប់សាលាអប់រំជំនឿសន្តយ៉ូស្វីននៅក្នុងជំនាន់ទី៤នេះ។ សម្តេចប៉ាប យ៉ូហានទី២៣ នៅពេលគេជ្រើសរើសគាត់គឺគេជ្រើសរើសសម្តេចប៉ាបម្នាក់ដែលចាស់ មានអាយុ៧៨ឆ្នាំ គាត់បន្តពីសម្តេចប៉ាប ភីយូស ទី១២។ សម្តេចប៉ាប ភីយូស ទី១២ បានធ្វើជាសម្តេចប៉ាបយូរឆ្នាំណាស់ គាត់បានឆ្លងសង្គ្រាមលោកលើកទី២ ដូច្នេះគេគិតថាគេត្រូវការជ្រើសរើសសម្តេចប៉ាបម្នាក់ទៀត ដែលចាស់ហើយដើម្បីសម្រុះសម្រួលក្នុងអន្តរកាលមុនមានសម័យថ្មី។ ដូច្នេះគេបានជ្រើសរើស យ៉ូហានទី២៣ ដែលជាលោកតាម្នាក់ដែលគួរឲ្យស្រឡាញ់ នៅពេលគាត់ដើរតាមព្រះសហគមន៍នីមួយៗនៅទីក្រុងរ៉ូម គាត់ទៅជួបជាមួយកូនក្មេង ឲ្យស្ករគ្រាប់ទៅកូនក្មេង ទៅមន្ទីរពេទ្យលើកទឹកចិត្តអ្នកជំងឺ។

ប៉ុន្តែ សម្តេចប៉ាបនេះ បានណែនាំឲ្យព្រះសហគមន៍ជាពិសេសក្រុមប្រឹក្សាជាន់ខ្ពស់របស់សម្តេចប៉ាប (កាឌីណាល់) ភ្ញាក់មែនទែនដោយសារគាត់ដូចជាស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធដែលបំភ្លឺគាត់។ នៅព្រឹកមួយ ពេលគាត់ទៅថ្វាយអភិបូជាគាត់នឹកឃើញព្រះសហគមន៍របស់យើងបីដូចជាធ្វើដំណើរឆ្ងាយពីពិភពលោកមែនទែន យើងមានពិធីបុណ្យអភិបូជា យើងមានការអប់រំជំនឿ យើងរស់នៅជាគ្រីស្តបរិស័ទ ប៉ុន្តែសង្គមរបស់យើងបានអភិវឌ្ឍន៍លឿន តែព្រះសហគមន៍របស់យើងស្ថិតស្ថេរដដែលៗ។ គាត់មានអារម្មណ៍ថា ព្រះសហគមន៍ដូចជាធ្វើដំណើរខ្លួនឯងនិងពិភព

លោកចាប់ផ្តើមរីកចម្រើនលឿនមែនទែន ពិភពលោកដូចជាពិភពថ្មីតែព្រះសហគមន៍ដូចជាដដែលៗ។ ពេលគាត់កំពុងអធិដ្ឋានមុនចូលអភិបូជា គាត់នឹកឃើញថា យើងត្រូវការរីកចម្រើន ដើម្បីឲ្យព្រះសហគមន៍ចាប់ផ្តើមចូលជាមួយពិភពដែលកំពុងកើតឡើងនៅមុខយើង។ នៅពេលនោះគាត់សម្រេចចិត្តបង្កើតមហាសន្និបាតវ៉ាទីកង់ទី២ ជាមហាសន្និបាតនៃព្រះសហគមន៍ទី២១ ដែលណែនាំឲ្យលោកអភិបាលទាំងអស់នៅក្នុងពិភពលោកមកជួបជុំគ្នា។

នៅពេលសម្តេចប៉ាប និយាយទៅក្រុមប្រឹក្សាជាន់ខ្ពស់ គេភ្ញាក់ដោយគិតថា "**តើគាត់ចង់ធ្វើអ្វី? យើងបានជ្រើសរើសលោកតាម្នាក់ឲ្យគាត់នៅស្ងៀមស្ងាត់ ឥឡូវនេះគាត់កំពុងរៀបចំប្រជុំដែលណែនាំឲ្យលោកអភិបាលទូទាំងពិភពលោកមកជួបជុំគ្នា ដើម្បីគិតអំពីព្រះសហគមន៍យើង**" មានលោកកាឌីណាល់មួយចំនួនបានឯកភាពតាមសម្តេចប៉ាប។ គណកម្មការរៀបចំកម្មវិធីប្រជុំនេះបានរៀបចំប្រធានបទ សំណួរ និងឯកសារនានាទុកជាមុនទាំងអស់។ ក្រោយមកលោកអភិបាលទូទាំងពិភពលោកបានមកប្រហែល១៥០០នាក់ទៅ២០០០នាក់ ដែលជួបជុំគ្នានៅវ៉ាទីកង់ក្នុងនោះមានលោកអភិបាល អ៊ីវ រ៉ាមូស ដែលជាអភិបាលនៃព្រះសហគមន៍កាតូលិកនៅកម្ពុជា។ នៅពេលលោកកាឌីណាល់បានបង្ហាញប្រធានបទ សំណួរ និងឯកសារនានាដែលគេរៀបចំ មានលោកអភិបាលមួយចំនួនជាពិសេសលោកកាឌីណាល់មកពីអាឡឺម៉ង់ គាត់បានលើកដៃជំទាស់ថា "**សម្តេចប៉ាបឲ្យយើងបើកទ្វារនៃព្រះសហគមន៍ បើកបង្អួចនៃព្រះសហគមន៍ ដើម្បីខ្យល់នៃព្រះវិញ្ញាណដ៏វិសុទ្ធយាងចូលបាន បើយើងបានរៀបចំប្រធានបទ សំណួរ និងឯកសារនានាហើយ យើងមិនព្រម យើងត្រូវការគិតសាជាថ្មីទាំងអស់**"។ ដូច្នេះអ្វីដែលគណកម្មការបានរៀបចំចោលទាំងអស់ គេចាប់ផ្តើមគិតសាជាថ្មី គេប្រជុំពីឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៦៥ រយៈពេល៤ឆ្នាំនេះជួបគ្នាមួយឆ្នាំម្តង ដោយចាប់ផ្តើមគិតអំពីព្រះសហគមន៍ ព្រះសហគមន៍និងព្រះបន្ទូល ព្រះសហគមន៍និងពិធីបុណ្យ ព្រះសហគមន៍និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ព្រះសហគមន៍និងសាសនាដទៃព្រះសហគមន៍មានទំនាក់ទំនងជាមួយពិភពដែលកំពុងកើតឡើង ជាពិសេសចុងក្រោយគេបានគិតអំពី អំណរសប្បាយនិងសេចក្តីសុខសាន្តនៃពិភពលោក ជាអំណរសប្បាយនិងសេចក្តីសុខសាន្តនៃព្រះសហគមន៍។ គេបានបង្កើតឯកសារមួយ ដែលណែនាំឲ្យព្រះសហគមន៍អាចចូលជាមួយពិភពលោកដែរ **ធ្វើយ៉ាងម៉េចដើម្បីឲ្យទុក្ខលំបាកនិងអំណរសប្បាយនៃមនុស្សលោក ទៅជាទុក្ខលំបាកនិងអំណរសប្បាយរបស់ព្រះសហគមន៍? ធ្វើយ៉ាងម៉េចដើម្បីឲ្យទុក្ខព្រួយនឹងសេចក្តីសង្ឃឹមនៃពិភពលោក ទៅជាទុក្ខព្រួយនិងសេចក្តីសង្ឃឹមរបស់ព្រះសហគមន៍?** ក្រុមលោកអភិបាលបានប្រជុំដែលណែនាំឲ្យព្រះសហគមន៍មានរបៀបថ្មី ដើម្បីបង្កើតទំនាក់ទំនងជាមួយ

សាសនាដទៃ ជាមួយវិទ្យាសាស្ត្រ ជាមួយពិភពលោក **ធ្វើយ៉ាងណាដើម្បីឲ្យព្រះសហគមន៍ប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ នៅក្នុងរបៀបបច្ចុប្បន្ននេះ?** នេះជាចំណុចទីមួយ។

ចំណុចទីពីរ ឲ្យយើងធ្វើយ៉ាងណាដើម្បីយកចិត្តទុកដាក់និងជីវិតរបស់មនុស្សលោក ជីវិតរបស់ពិភពលោក **ខ្ញុំជាគ្រីស្តបរិស័ទតើខ្ញុំធ្វើយ៉ាងណាដើម្បីឲ្យបងប្អូនឯទៀតៗទទួលនិងអាចស្តាប់បាន? ធ្វើយ៉ាងណាឲ្យជីវិតរបស់យើងទៅជាសក្ខីភាពយ៉ាងពិសេស ដែលមានឥទ្ធិពលលើបងប្អូនឯទៀតៗ?** នេះជាអ្វីដែលយ៉ូហានទី២៣បានធ្វើ លោកជាសម្តេចប៉ាបដ៏អស្ចារ្យដែលបានណែនាំឲ្យព្រះសហគមន៍មានជីវិតថ្មី មានកម្លាំងថ្មីដើម្បីប្រកាសជំនឿ។ មុនសម្តេចប៉ាប យ៉ូហានទី២៣សោយទិវង្គតគាត់បានសរសេរលិខិតយ៉ាងឱឡារិក ដែលទាក់ទងនឹងសុខសន្តិភាពនៅលើផែនដី។ ដោយសារ គាត់ឃើញយើងបានចេញពីសង្គ្រាមលោកលើកទីពីរហើយ ប៉ុន្តែនៅសម័យនោះរុស្ស៊ីជាមួយអាមេរិកបានបង្កើតសង្គ្រាមត្រជាក់ គាត់ចាប់ផ្តើមព្រួយបារម្ភណ៍ ដោយកម្លាំងដែលគាត់នៅសល់គាត់បានសរសេរលិខិតមួយផ្ញើជូនដល់មនុស្សលោកទាំងអស់ ដែលមានចំណងជើងថា "**សេចក្តីសុខសាន្តនៅលើផែនដី**" ធ្វើយ៉ាងណាឲ្យពិភពលោកយើងលែងមានសង្គ្រាម ធ្វើយ៉ាងណាឲ្យយើងប្រគល់ពិភពដល់កូនចៅរបស់យើង ជាពិភពដែលប្រកបដោយសេចក្តីសុខសាន្តយ៉ាងពិតប្រាកដមែន។ **តើធ្វើយ៉ាងណាឲ្យយើងជាគ្រីស្តបរិស័ទទៅជាទូតនៃសេចក្តីសុខសាន្ត?**

ចំណុចទីបី ទុកឲ្យយើងយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ កុំឲ្យយើងធ្វើតាមចិត្ត កុំឲ្យយើងធ្វើតាមគម្រោងការណ៍របស់យើង ទុកឲ្យព្រះវិញ្ញាណដ៏វិសុទ្ធមានកន្លែងនៅក្នុងដួងចិត្តនៅក្នុងជីវិតរបស់យើង ដើម្បីឲ្យយើងចូលនៅក្នុងគម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ សម្តេចប៉ាបយ៉ូហានទី២៣ ចាស់ហើយពេលគេជ្រើសរើសគាត់ជាសម្តេចប៉ាប គាត់បានឯកភាពដោយសារគាត់គិតថានៃជាគម្រោងការណ៍របស់ព្រះជាម្ចាស់។ នៅពេលគាត់នឹកឃើញបង្កើតឲ្យមានមហាសន្និបាតវ៉ាទីកង់ទីពីរ ដោយសារមានព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលគាត់សរសេរលិខិតដើម្បីឲ្យមនុស្សលោកបញ្ចប់សង្គ្រាម ឲ្យយើងរួមរស់ជាគ្រួសារមួយដើម្បីបង្កើតសេចក្តីសុខសាន្ត មានព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។ ដូច្នេះឲ្យសាលាសន្តយ៉ូស្វីនកុំឲ្យយើងរស់នៅតាមកាលៈទេសៈ ប៉ុន្តែនៅក្នុងកាលៈទេសៈមានព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅ។ សាលារបស់យើងមានគម្រោងការណ៍ច្រើន ប៉ុន្តែអ្វីដែលសំខាន់ទុកឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងចូល ដើម្បីឲ្យយើងបង្កើតព្រះសហគមន៍របស់យើងដែលចេះបង្ហាញសេចក្តីស្រឡាញ់ បង្ហាញយុត្តិធម៌ បង្ហាញសេចក្តីសុខសាន្ត និងណែនាំឲ្យមនុស្សយើងអាចបានកម្លាំងថ្មីដើម្បីកសាងពិភពថ្មី។ អាម៉ែន៕